# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមីនា ឆ្នាំ២០២០

នៅក្នុងខែមីនា ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ:

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ ៖**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០១លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ ៖**

-អនុញ្ញាតឱ្យលោកជំទាវ **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងគណៈប្រតិភូស្ត្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន១៥០នាក់ ចូលជួបសម្តែងការគួរសម ក្នុងពិធីអបអរសាទរខួបលើកទី១០៩ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២០។

**គ-សកម្មភាពចូលរួមពិធីផ្សេងៗ ៖**

-អញ្ជើញចូលរួមក្នុងពិធីបុណ្យបច្ច័យបួន និងបុណ្យចំរើនជន្មាយុ៦៩ឆ្នាំ ឈានចូល៧០ឆ្នាំជូនឧបាសិកា **សាយ យូអឿន** ម្តាយរបស់លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធាន នៅបុរីប៉េងហួតបឹងស្នោរ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា ពុទ្ធាភិសេក និងសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តពោធិជ័យ ក្នុងឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

**ឃ-សកម្មភាពចុះមូលដ្ឋាន ៖**

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះ និង



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ចុះពិនិត្យសាលាបឋមសិក្សាសៀមប៉ាង ជាទីកន្លែងដែលសម្តេចធ្លាប់បំពេញការងារ ហើយបានជួបសំណេះសំណាលជាមួយអតីតគ្រូបង្រៀន និងសិស្សចាស់ៗរបស់សម្តេច កាលពីទសវត្សរ៍ទី៦០ នៅឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៨ច្បាប់ និង ជ្រាបជាព័ត៌មានចំនួន៣៨ច្បាប់។

**១.២ ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ៖**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និង កិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០១លើក

-អញ្ជើញចូលរួមប្រជុំក្រុមសមាជិករដ្ឋសភា-ព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-អញ្ជើញចូលរួមប្រជុំផ្ទៃក្នុងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនា-ភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

**ខ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៦ច្បាប់ និង ជ្រាបជាព័ត៌មានចំនួន៣៦ច្បាប់។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ ៖**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និង កិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០១លើក។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ៖**

-អញ្ជើញចូលរួមក្នុងកម្មវិធីស្រោចស្រពព្រះសុគន្ធវារីប្រគេនសម្តេចព្រះសង្ឃ នាយករងពីរអង្គ ដែលព្រះមហាក្សត្រទើបត្រាស់បង្គាប់តែងតាំងថ្មី ដែលប្រារព្ធនៅ វត្តមុនីសុវណ្ណហៅវត្តចំពុះក្អែកក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនា-បតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមក្នុងកម្មវិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលនានានៅវត្តពោធិជ័យ ក្នុងឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធាន ព្រឹទ្ធសភា

-អញ្ជើញចូលរួមក្នុងពិធីបុណ្យសពឧបាសិកា **ប៉ាន បូផា** ក្នុងបុរីប៉េងហួតបឹងស្នោរ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរឃុំក្រាំងយ៉ូវ ដោយបានពន្យល់ណែនាំអំពីរបៀបថែទាំសុខភាព អនាម័យ ដើម្បីបញ្ចៀសការឆ្លងជំងឺកូវីដ១៩ ព្រមទាំងបានឧបត្ថម្ភទឹកអាល់កុល និងម៉ាស់មួយចំនួនផងដែរ។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១០ច្បាប់។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក:**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំចំនួន០២លើក ដែលមានរបៀបវារៈដូចខាងក្រោម:

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីពីរស្តីពី វិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថានសុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីបីស្តីពី វិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

៤-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី១ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន

៥-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

៦-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

**៣.សម័យប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០១លើក** :

ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

២-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីមួយ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីពីរ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីបី ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា :

ក្នុងខែមីនានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

### ៤.១ មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-អញ្ជើញជួបជាមួយឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមសមាគមអ្នកចិញ្ចឹមសត្វកម្ពុជា ដើម្បីពិភាក្សា និងជំរុញការចិញ្ចឹមជ្រូកឱ្យបានកាន់តែច្រើន ដើម្បីបំពេញតម្រូវការទីផ្សារឱ្យបានគ្រប់គ្រាន់ ឈានទៅកាត់បន្ថយការនាំចូលជ្រូកមកពីប្រទេសនានា

-អញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងបុព្វបទថ្មី ពិសេសការងារចាត់តាំង ការអនុវត្តថវិកា ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ នៅខេត្តពោធិ៍សាត់

-អញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់ការងារពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈ-កម្មការ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដោយផ្តោតលើគម្រោងអភិវឌ្ឍន៍ផ្លូវថ្នល់ ផ្លូវដែក និងកំពុងផែទឹកជ្រៅ ខេត្តព្រះសីហនុ ដំណើរការរោងចក្រផលិតថាមពលអគ្គិសនីដុតធ្យូងថ្ម នៅស្រុកស្ទឹងហាវ និងដោះស្រាយផលប៉ះពាល់បរិស្ថានពាក់ព័ន្ធនឹងការអភិវឌ្ឍក្រុង និងពិនិត្យលើដំណោះស្រាយផលប៉ះពាល់ពីការអភិវឌ្ឍទីក្រុងតំបន់ឆ្នេរ ការរៀបចំដែនដី និងនគរូបនីយកម្ម ខេត្តព្រះសីហនុ

-អញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មាន ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ស្ពឺ។

### ៤.២ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន០៣ករណី ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹងពីចំណាត់ការរបស់គណៈកម្មការបានចំនួន០៣ករណី កំពុងពិនិត្យសិក្សាបានចំនួន០៤ករណី និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការ ដើម្បីជូនជ្រាបបានចំនួន១០ករណី

-បានប្រជុំផ្សព្វផ្សាយស្តីពី ការចូលរួមអនុវត្តខ្លឹមសារសេចក្តីស្តីពី ការបង្ការទប់

ស្កាត់ជំងឺកូវីដ-១៩ ដល់ថ្នាក់ដឹកនាំឥស្លាមទាំងអស់ក្នុងខេត្តកំពត ដែលមានសមាសភាពចូលរួមចំនួន១៣៨នាក់

-អញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយក្រុមប្រឹក្សាស្រុកត្បូងឃ្មុំ អំពីការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ និងការអនុវត្តគោលនយោបាយភូមិឃុំ មានសុវត្ថិភាព នៅខេត្តត្បូងឃ្មុំ

-អញ្ជើញចូលរួមសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២០ ក្រោមប្រធានបទកិច្ចសហការក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទីក្រុងឆ្លាតនាពេលអនាគត

-អញ្ជើញចូលរួមជាអធិបតីនៃទិវា " ASEM DAY " និងការដាក់តាំងស្តង់របស់ក្រុមការងារSlideEvents ទាំង៧ដើម្បីបង្កើនការយល់ដឹងអំពីកិច្ចប្រជុំអាស៊ី-អឺរ៉ុប ដល់និស្សិត និងពលរដ្ឋកម្ពុជាអំពីការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី១៣ក្នុងឆ្នាំ២០២០

-អញ្ជើញចូលរួមទស្សនា និងផ្តល់យោបល់លើខ្សែវីដេអូព្រឹទ្ធសភាស្តីពីវឌ្ឍនភាពឆ្នាំទី២ នៃព្រឹទ្ធសភា នីតិកាលទី៤

-អញ្ជើញចូលរួមប្រជុំពិនិត្យ និងពិភាក្សាលើការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

-អញ្ជើញជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៅស្រុកបន្ទាយអំពិល ដើម្បីឈ្វេងយល់អំពីការផ្តល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន មូលនិធិអភិវឌ្ឍឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព នៅខេត្តឧត្តរមានជ័យ

-អញ្ជើញជួបពិភាក្សាការងារជាមួយលោក Nicolas Dervaux តំណាងឱ្យរដ្ឋាភិបាលវ៉ាល់ឡូនីព្រុចសែលបែលហ្ស៊ិក ប្រចាំនៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញចូលរួមកម្មវិធីយុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅភាពជាអ្នកដឹកនាំ

-អញ្ជើញចុះជួបសំណេះសំណាលជាមួយលោកគ្រូអ្នកគ្រូចំនួន៨៧នាក់ នៅវិទ្យាល័យហ៊ុន សែន ចំបក់ ដើម្បីឈ្វេងយល់អំពីកម្មវិធីសិក្សា និងការអប់រំ ផ្សព្វផ្សាយវិធីការពារជំងឺកូវីដ-១៩ និងបានឧបត្ថម្ភជូនលោកគ្រូ អ្នកគ្រូ ក្នុងម្នាក់ៗថវិកាចំនួន ២០.០០០រៀល នៅភូមិវល្លិសរ ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

-អញ្ជើញសម្ពោធអណ្ដូងទឹកស្អាតចំនួន៩កន្លែង ដែលជាអំណោយរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ជូនប្រជាពលរដ្ឋ នៅភូមិត្រពាំងថ្ម ឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប

-អញ្ជើញសំណេះសំណាល និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់សមាគមបេសកកម្មសិក្សាអាស៊ី (AMSA) ប្រទេសបារាំង និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជារបស់ប្រទេសបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្ដាល ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

-អញ្ជើញចូលរួមវគ្គផ្សព្វផ្សាយការងារស្វែងយល់អំពីនីតិវិធីពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឧទ្ទេសនាមដោយឯកឧត្តម **សោម សូរីដា** អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសហការី

-អញ្ជើញចូលរួមកម្មវិធីបុណ្យបញ្ចុះខណ្ឌសីមានៅវត្តពោធិជ័យ ឃុំសេកុង ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ក្រោមអធិបតីភាពសម្ដេចប្រធានព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងចំនួន៦៥លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខ និងផ្សព្វផ្សាយវិធីបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ ដល់ប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុបចំនួន៨៩លើក។

ថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០

**ជ.ប្រធានស្ដីទីព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

**ចម្លងជូន**

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*